# គម្រោងបរិស្ថានថ្មីៗដែលគ្រោងសម្រាប់មហាអនុតំបន់មេគង្គ

**ក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា ៖** គម្រោងដែលបានស្នើឡើងសម្រាប់កិច្ចសហប្រតិបត្តិការបរិស្ថានថ្នាក់តំបន់ ត្រូវបានមន្ត្រីជាន់ខ្ពស់មកពីបណ្តាប្រទេសមហាអនុតំបន់មេគង្គ (GMS) ទាំង៦ យកមកធ្វើការពិភាក្សា នៅឯព្រឹត្តិការណ៍មួយស្តីពី "កំណើនសេដ្ឋកិច្ចដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន" ដែលប្រារព្វធ្វើឡើងនៅក្រុងសៀមរាបកាលពីថ្ងៃទី១១ ខែកក្កដា។

អ្វីដែលបានដាក់បញ្ចូលក្នុងការពិភាក្សា រួមមានកម្មវិធីថ្នាក់តំបន់សម្រាប់ការគ្រប់គ្រងកាកសំណល់នៅតំបន់ជនបទ និង ការគ្រប់គ្រងដីប្រកបដោយនិរន្តរភាព ព្រមទាំងការផ្តួចផ្តើមជាក់លាក់ដែលកំណត់គោលដៅទៅលើភាពធន់នឹង ការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍ដែលបំភាយកាបូនក្នុងកម្រិតទាប និង ការត្រួតពិនិត្យទៅលើការបំពុលបរិស្ថាន។

"ដំណើរការ" គម្រោង ដែលត្រូវបានអភិវឌ្ឍន៍ឡើងរួមគ្នា រវាងកម្មវិធីបរិស្ថានស្នូល (CEP) នៃមហាអនុតំបន់មេគង្គ ដែលដឹកនាំដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ក្រសួងបរិស្ថានទាំង៦ នឹងត្រូវបានយកមកធ្វើការកែសម្រួលបន្ថែមទៀត មុនពេលដាក់ជូនដើម្បីសុំការអនុម័តនៅឯកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីបរិស្ថាននៃមហាអនុតំបន់មេគង្គ លើកទី៥ ដែលនឹងប្រារព្វធ្វើឡើងនៅក្រុងសៀមរាប ក្នុងខែកុម្ភៈ ឆ្នាំក្រោយនេះ។

Pavit Ramachandran មន្ត្រីឯកទេសជាន់ខ្ពស់ផ្នែកបរិស្ថាន នៃធនាគារអភិវឌ្ឍន៍អាស៊ី បានមានប្រសាសន៍ឱ្យដឹងថា "គម្រោងបរិស្ថានទាំងនេះ នឹងជួយដល់បណ្តាប្រទេសមហាអនុតំបន់មេគង្គបោះជំហានឆ្ពោះទៅរកមាគ៌ាកំណើនសេដ្ឋកិច្ចដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន ព្រមទាំងរួមចំណែកដល់ការសម្រេចឱ្យបាននូវការប្តេជ្ញាចិត្តចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នៅកម្រិតថ្នាក់ជាតិរបស់ពួកគេ។ យើងកំពុងពិនិត្យស្វែងរកលទ្ធភាពអភិវឌ្ឍន៍គម្រោងគួរឱ្យជឿជាក់បាន ដែលមានសក្តានុពលក្នុងការទទួលបានថវិកាគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ឬ ដៃគូដៃទៀត"។

Ramachandran បានបន្ថែមទៀតថា កម្មវិធីបរិស្ថានស្នូល ដែលជាកម្មវិធីកម្មវិធីសហប្រតិបត្តិការបរិស្ថានឈានមុខគេសម្រាប់មហាអនុតំបន់មេគង្គ នឹងដើរតួនាទីមួយដ៏សំខាន់ក្នុងការគៀងគរមូលនិធិ និង ផ្តល់ជំនួសបច្ចេកទេស ដើម្បីធ្វើឱ្យដំណើរការនេះមានប្រតិបត្តិការទៅបាន។

ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា គឺជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍នេះ ព្រមទាំងបាននាំមកនូវជំនាញការផ្នែកបរិស្ថានថ្នាក់តំបន់ និង អន្តរជាតិ ដើម្បីធ្វើការចែករំលែកការអនុវត្តល្អ អំពីអភិក្រម និង ឧបករណ៍ស្តីពីកំណើនសេដ្ឋកិច្ចដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន។

ឯកឧត្តម **សៅ សុភាព** ទីប្រឹក្សា និងជានាយកខុទ្ទកាល័យនៃក្រសួងបរិស្ថាន បានមានប្រសាសន៍ឱ្យដឹងថា "ប្រទេសកម្ពុជាមានសេចក្តីរីករាយក្នុងការទទួលធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍នេះ ហើយគម្រោងដែលបានស្នើឡើងទាំងនេះ ព្រមទាំងការចែករំលែកបទពិសោធន៍អន្តរជាតិ ផ្តល់នូវកម្លាំងចលករបន្ថែមទៀតសម្រាប់ដំណើររួមគ្នារបស់យើង ឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន នៅក្នុងមហាអនុតំបន់មេគង្គ"។

មន្ត្រីបរិស្ថានជាន់ខ្ពស់ និង អ្នកតំណាងធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានជួបជុំគ្នានៅថ្ងៃទី១២ ខែកក្កដា នៅក្រុងសៀមរាបផងដែរ សម្រាប់កិច្ចប្រជុំប្រចាំឆ្នាំលើកទី២៣ របស់ក្រុមការងារបរិស្ថាននៃមហាអនុតំបន់មេគង្គ។ នៅក្នុងកិច្ចប្រជុំនេះ ពួកគេបានពិនិត្យឡើងវិញទៅលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីបរិស្ថានស្នូល ព្រមទាំងបានពិភាក្សាអំពីក្របខ័ណ្ឌយុទ្ធសាស្រ្តមួយ សម្រាប់កម្មវិធីដំណាក់កាលទី៣ ឆ្នាំ២០១៨-២០២២។

មហាអនុតំបន់មេគង្គរួមមាន ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន (ជាពិសេសគឺខេត្ត Yunnan និង តំបន់ស្វយ័ត Guangxi Zhuang) សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសមីយ៉ាន់ម៉ា ប្រទេសថៃ និង ប្រទេសវៀតណាម។